# ការសម្ភាសរបស់អ៊ុំស្រី សុខ កង

កះ អ្នកធ្វើការសំភាសន៍ឈ្មោះ ហេង សុជីវី ខះ អ្នកត្រូវគេសំភាសន៍ឈ្មោះ សុខ កង

កះ ជាដំបូងសូមជំរាបសួរជាដំបូងសូមជំរាបសួរអ៊ុំ!!

ខះ ចាស!ជំរាបសួរចាស!

កះ ចាស!អ៊ុំថ្ងៃនេះខ្ញុំមានឪកាសដើម្បីនឹងមកធ្វើការសំភាសន៍អ៊ុំផ្ទាល់ ខ្ញុំបានធ្វើការងារស្មាគចិត្តរបស់គំរោងនៅក្នុងខាងសាលាBYU Hawiaនៅក្នុងសហរដ្ឋអាមេរិកហើយគំរោងរបស់ខាងសាលា គេបានធ្វើទាក់ទងទៅនឹងខាងសំភាសន៍ទៅដល់ប្រជាជនកម្ពុជាដែលគាត់មានវ័យចាប់ពីអាយុ៣៥ឡើងជាមួយនឹងប្រវត្តិរបស់គាត់និងបទពិសោធន៍របស់គាត់នឹងបទពិសោធន៍ជីវិតរបស់គាត់ពេលដែលគាត់អីកាលដែលគាត់បានកើតនៅក្នុងជំនាន់ពពត នឹងនៅក្នុងជំនាន់ផ្សេងៗទៀតដែលគាត់ធ្លាប់បានជួបប្រទះណាដូចជាកាលនៅក្នុងសម័យកាលពីមុននឹងគាត់បានជួបប្រទះថាអូកាលនឹងវាមានការលំបាកបែបយ៉ាងម៉េចខ្លះហើយបានជាធ្វើអោយអ៊ុំបានតស៊ូនៅក្នុងជីវិតរបស់អ៊ុំហើយដល់ពេលដែលមាននៅក្នុងសព្វថ្ងៃនេះមកនឹងណាអ៊ុំ។

ខះចាស!!

កះ
ចឹងថ្ងៃនេះខ្ញុំមានឪកាសដើម្បីនឹងធ្វើការសំភាសន៍អ៊ុំស្រីផ្ទាល់ចឹងវាពិតជាសំណាងមែនទែនចឹងហើយតើអ៊ុំនឹងអនុញ្ញាតនឹងអោយខ្ញុំបានធ្វើការសំភាសន៍ដល់អ៊ុំស្រីដែលឬទេ?

ខះ និយាយរឿងនឹងកាលពីប្រវត្តិមកនឹងហោស?

កះ ចាសអ៊ុំ!

ខះ ប្រវត្តិកាលពីមុនមកនឹងវារាងពិបាកតិចហើយ។

កៈ ចាស!អ៊ុំ

ខៈ វាមិនបាន ដូចជានៅក្នុងកាលនៅសម័យនេះឥឡូវនឹងទេវាជាសម័យជឿនលឿនចឹង។

កៈ ចាស ចាស

ខៈ នឹងហើយ

កៈ ចឹងខ្ញុំសូមដើម្បីនឹងសូមធ្វើការអនុញ្ញាតអំពីអ៊ុំនឹងធ្វើការថតសំលេងរបស់អ៊ុំបានដែរឬទេ?

ខៈ ចាសថតសំលេងរបស់អ៊ុំនឹងហោស?

កៈ
ចាសថតសំលេងរបស់អ៊ុំដែលបាននិយាយនឹង។ព្រោះអីសំលេងរបស់អ៊ុំស្រីមួយនឹងខ្ញុំនឹងយកទៅធ្វើការថតចំលងនឹងកមានជាការដែលគេបានយកទៅដាក់នៅក្នុងខាងវេបសាយរបស់ខាងសាលានៅខាងសហរដ្ឋអាមេរិកអោយគេបានដឹងណា។

ខៈ
ចាសចឹងមានទៅស្អីការងារយើងនឹងណែដែលត្រូវជឿនលឿនទៅមុខនឹងវាមានទៅមានបញ្ហាស្អីនោះទេកុំអោយតែយើងមកដូចថាយើងបានដើរសំភាសន៍ហើយនឹងយកទៅបោះចោលចូលទៅក្នុងព្រៃឯណាអានឹងបានវាខាតពេលវេលា។

កៈ ចាសត្រឹមត្រូវហើយអ៊ុំហឹស។

ខៈ ចាសៗ

កៈ ចឹងយើងមិនបានធ្វើការសំភាសន៍ហើយយកទៅបោះចោលនោះទេ
កាលសំភាសន៍១នឹងគេបានធ្វើឡើងដើម្បីជួយប្រជាជនកម្ពុជាដើម្បីនឹងចង់ក្រងឯសារប្រវត្តិរបស់គាត់ទុកហើយគេនឹងធ្វើការបកប្រែ១ដងទៀតហើយគេបានពិនិត្យមើលរួចអស់ហើយបានជាគេសរសេរជាភាសាអង្គ្លេស១ដងទៀតហើយបានជាគេនឹងធ្វើការយកទៅpostនៅក្នុងវេបសាយអោយគេបានដឹងជាសាធារណៈអោយគេបានដឹង។

ខ៖ ចាសៗ

ក៖ ចឹងថ្ងៃនេះគឺជាថ្ងៃទី១៤ ខែ៦ ឆ្នាំ២០១៨ហើយខ្ញុំបានធ្វើការសំភាសន៍ទៅដល់អ៊ុំស្រីផ្ទាល់ចឹងជាដំបូងសូមសួរអ៊ុំតើអ៊ុំស្រីមានឈ្មោះអ្វីដែរ?

ខ៖ ខ្ញុំឈ្មោះថា សុខ កង។

ក៖ ចាសហើយអ៊ុំស្រីនេះជាឈ្មោះពេញដែរឬទេ?

ខ៖ ចាស!!

ក៖ ចាសឈ្មោះនេះវាពេញដែលឬទេ?

ខ៖ ចាសឈ្មោះនេះគ្មានដែលបានប្តូរបានផ្លាស់ទេឈ្មោះនឹងត្រូវហើយប្រើតាំងពីកំណើរមក។

ក៖ ឈ្មោះនឹងត្រូវជាមួយនឹងអត្តសញ្ញាប័ណ្ណដែរឬទេអ៊ុំ?

ខ៖ ចាសឈ្មោះនឹងត្រូវជាមួយនឹងអត្តសញ្ញាតប័ណ្ណ ព្រោះអីនៅក្នុងអត្តសញ្ញាតប័ណ្ណនឹងក៏បានដាក់ឈ្មោះនឹងដែរ។

ក៖ ចាសហើយ..

ខ៖ តាំងពីឪពុកម្តាយគាត់ជាអ្នកដែលបានដាក់ឈ្មោះនឹងអោយ។

ក៖ ចាសហើយទៅចំណែកឯឈ្មោះអ៊ុំមានឈ្មោះហៅក្រៅដែលឬទេ?

ខ៖ អត់

ក៖ អត់មានទេចឹង។

ខ៖ អត់មានទេមានតែឈ្មោះនឹងតែ១គត់នឹងតែម្តង។

ក៖ ចាសហើយចឹងតើឈ្មោះនឹងតើនរណាគេដែលបានដាក់ឈ្មោះនឹងអោយអ៊ុំ?

ខ៖ ឪពុកម្តាយខ្ញុំគាត់ជាអ្នកដែលបានដាក់អោយ។

កៈ ចាស

ខៈ នឹងហើយ

កៈ ចាស អូ ចាសហើយចុះសព្វថ្ងៃនឹងតើអ៊ុំមានអាយុបានប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំសព្វថ្ងៃនឹងខ្ញុំមានអាយុបាន៦២ឆ្នាំហើយ។

កៈ អូចឹងតើអ៊ុំមានបានចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនដែរឬទេ?

ខៈ
ហឹសៗខ្ញុំបានចាំតែឆ្នាំនោះទេអត់បានមានដឹងថានៅក្នុង២០០០អីប៉ុន្មានអីប៉ុន្មាននោះទេហេស
។

កៈ អ៊ុំកើតនៅក្នុងនៅឆ្នាំណាដែលអ៊ុំ?

ខៈ ខ្ញុំកើតនៅក្នុងឆ្នាំរការរងណោះ។

កៈ ចឹងអ៊ុំមានបានដាក់អត្តសញ្ញាប័ណ្ណរបស់អ៊ុំបានដែលឬទេ?

ខៈ យកមកតើ។

កៈ ចឹងខ្ញុំសូមថតអត្តសញ្ញាប័ណ្ណរបស់អ៊ុំ១ដើម្បី១នឹងទុកជា
គេបានចង់ក្រង់ប្រវត្តិរបស់អ៊ុំចឹងហើយគេបានដឹងអំពីថ្ងៃខែកំណើតរបស់អ៊ុំវាស្រួលគេនឹងធ្វើកា
រអឹទុកវា។

ខៈ
ខ្ញុំអានឹងជាអត្តសញ្ញាប័ណ្ណអាចាស់នោះទេហើយអាថ្មីនឹងខ្ញុំបានប្រើអាថ្មីនឹងវាមិនទាន់បានទេ
ដូចថាវាបានឆេះអស់ទៅនឹងហើយខ្ញុំបាននៅប្រើតែអាចាស់នឹងសិន
ដូចថាគេប្រាប់ថាពេលដែលទៅបោះឆ្នោតនឹងក៏អាចយកទៅនឹងទៅ
គេបានអោយយកអានឹងទៅទៅវាប្រើការកើត។

(មានសំលេងថតជាកាម៉េកាគ្រឹម)

កៈ
ចាសអ៊ុំចឹងសូមអរគុណអ៊ុំខ្ញុំបានធ្វើការថតរួចរាល់អស់ហើយចឹងខ្ញុំសូមជូនអ៊ុំស្រីវិញណាអ៊ុំចាស។

ខៈ ចាសអត់អីនោះទេ។

កៈ
ចឹងខ្ញុំសូមធ្វើការសួរអ៊ុំស្រីបន្តទៀតថាតើអ៊ុំមានទីលំនៅកំណើតតើអ៊ុំស្រីមានទីលំនៅកំណើតនៅឯណាដែរ?

ខៈ ខ្ញុំនៅឃុំចំប៉ា។

កៈ សូមបញ្ជាក់ភូមិ ឃុំនឹងស្រុក ខេត្តអីបានដែលឬទេអ៊ុំ?

ខៈ នៅខេត្តតាកែវ នៅស្រុកព្រៃកក្របាស ឃុំភូមិចំប៉ា។

កៈ ចាស

ខៈ នៅឃុំសំរោង។

កៈ ចាសអ៊ុំហើយចុះសព្វថ្ងៃនឹងតើអ៊ុំមានទីលំនៅឯណាដែរ?

ខៈ មានទីលំនៅនឹងនោះឯង នៅក្នុងឃុំសំរោងនឹងតែម្តង។

កៈ អូអ៊ុំអត់មានធ្លាប់បានផ្លាស់ប្តូរទីលំនៅទេណ៎អ៊ុំ?

ខៈ ចាសអត់ដែលមានបានធ្លាប់បានផ្លាស់ប្តូរទីលំនៅផង។

កៈ ចាសហើយចុះសព្វថ្ងៃនឹងតើអ៊ុំមានក្រុមគ្រួសារហើយឬនៅ?

ខៈ ចាស?

កៈ តើអ៊ុំមានក្រុមគ្រួសារឬក៏មានភរិយាអីហើយឬនៅ?

ខៈ ខ្ញុំមានកូនវាមានដែរប៉ុន្តែវាបានបែកគ្នាអស់៥នាក់ហើយ។

កៈ ចាសចឹងអ៊ុំមានភរិយានៅក្នុងគ្រួសារណ៎អ៊ុំ ចឹងតើអ៊ុំបានរៀបការបានប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំបានរៀបការនឹងតាំងពីនៅក្នុងឆ្នាំ១៩៧៦មកនៅក្នុងខែ១ឯណោះ។

កៈ ចាសតើស្វាមីរបស់អ៊ុំ...

ខៈ ខ្ញុំបានរៀបការនឹងដោយសារតែអាពតនោះទេ។

កៈ
អូចឹងដោយសារតែពេលនឹងនោះអាពតគាត់បានជាអ្នកដែលរៀបការអោយអ៊ុំស្រីផ្ទាល់នោះទេកាលនឹងណ៎?

ខៈ ចាសអាពតនឹងគេជាអ្នកដែលបានរៀបការអោយ។

កៈ
ចឹងកាលនឹងអ៊ុំមិនមែនដោយសារតែអ៊ុំបានស្រលាញ់គ្នានោះទេណ៎អ៊ុំចឹងមិនមែនស្រលាញ់គ្នាដោយស្មាគចិត្តនោះទេ។

ខៈ
ទេអត់បានចឹងទេកាលនឹងដូចថាគាត់នឹងបាននៅនៅចំប៉ាឯនេះនឹងហើយខ្ញុំវិញនឹងខ្ញុំបាននៅឯនេះទេកាលនឹងខ្ញុំបាននៅឯក្បាលស្រែឯនោះនឹង។

កៈ ចាសៗ ហើយអ៊ុំខ្ញុំសូមធ្វើការសួរអ៊ុំស្រីថាអីអ៊ុំប្រុសគាត់មានឈ្មោះអ្វីដែរ?

ខៈ គាត់មានឈ្មោះថា សុខ មិត្រ។

កៈ ចាសហើយចុះតើគាត់មានទីលំនៅនៅឯណាដែរ?

ខៈ គាត់មានទីលំនៅនឹងនៅក្នុងឯស្រុកចំប៉ានៅឯក្នុងសំពោងដែលនឹង។

កៈ ចាសចឹងកាលនឹងអ៊ុំជាអ្នកជិតខាងគ្នាដែរចឹង?

ខៈ ចាសៗ

កៈ ហើយចឹងតើអ៊ុំស្រីសព្វថ្ងៃនឹងតើអ៊ុំមានកូនបានប៉ុន្មាននាក់ហើយ?

ខ៖ ខ្ញុំមានកូន៨នាក់។

ក៖ ចាសហើយចុះកូនរបស់អ៊ុំមានឈ្មោះអ្វីខ្លះដែរទៅអ៊ុំ?

ខ៖ កូននឹងហោស?

ក៖ ចាស កូនរបស់អ៊ុំនឹងគាត់មានឈ្មោះអ្វីខ្លះទៅ។

ខ៖ កូនៗនឹងមានអាបែកហើយនឹង? សួរទាំងអាបែកនឹងអាការហើយនឹងដែរ?

ក៖ ចាសអ៊ុំកូនៗរបស់អ៊ុំទាំងអស់នឹងតែម្តងកូនទាំង៨នាក់របស់អ៊ុំនឹងតែម្តង
ដែលកូនៗម្នាក់ៗនឹងអ៊ុំបានដាក់ឈ្មោះអោយពួកគាត់អ្វីខ្លះដែរខ្លះទៅ?

ខ៖ កូនៗនឹងមានឈ្មោះសំណាងមានឈ្មោះមុត
តែមុនដំបូងនឹងកូនបងគេបំផុតនឹងគេមានឈ្មោះថា សំណោត មេត
ហើយក្រោយមកនឹងគេមានឈ្មោះថាវ៉ាន់នី ឈ្មោះសំណាង ឈ្មោះស៊ីណាត មិននឹង។

ក៖ ចាស

ខ៖ អាស៊ីណង់ អាឡៃហៀងកូនខ្ញុំមាន៨នាក់នឹងស្រីមានតែ១នោះទេ។

ក៖ ចាស

ខ៖ ហើយសារៈ ហើយអើយអឺ

ក៖ ចាស

ខ៖ មានឈ្មោះទៀតគឺចាន់បរិមី ដែលជាកូនពៅគេ។

ក៖ ចាស ចឹងមិននឹងបានឈ្មោះកូនគ្រាប់គ្នាហើយណ៎អ៊ុំ?

ខ៖ បានគ្រាប់គ្នាហើយ។

ក៖ ចាសហើយចឹងអ៊ុំមានកូនស្រីបានប៉ុន្មានហើយកូនប្រុសបានប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំមានកូន៨នាក់នឹងកូនស្រីតែ១នាក់នោះទេ។

កៈ អឺចឹងចាសអ៊ុំចឹងអ៊ុំរាងខ្សោយកូនស្រីននណ៎អ៊ុំ ដោយសារអ៊ុំមានកូនស្រីតែ១នាក់ចឹង ហើយចឹងតើគាត់ជាកូនស្រីបងគេឬក៏ជាកូនស្រីកណ្តាលដែលម្តង?

ខៈ អត់គេជាកូនស្រីទី៦។

កៈ ទី៦ន៎អ៊ុំ?

ខៈ ចាស

កៈ អូហើយចុះសព្វថ្ងៃនឹងតើពួកគាត់មានមុខរបរជាអ្វីខ្លះដែរអ៊ុំ?

ខៈ
ហឺសធ្វើនឹងសព្វថ្ងៃនឹងគេមានការងារធ្វើនឹងធ្វើជាអ្នកសំណង់អីនឹងគ្មានបានមុខនឹងការងារអី នោះទេ គេធ្វើការងារសំណង់នឹងការងាររោងចក្រអីនឹង។

កៈហឺ!

ខៈ
ព្រោះអីយើងជាអ្នកក្រីក្រទៅរកស្អីបានបានទៅដូចជាមុខរបរអីទៅបានធំដុំអីនឹងទៅបានរកស៊ីអីដូចជាគេមានតែការទៅស៊ីឈ្នួលគេដូចថាការងាររោងចក្រចឹងទៅហើយមានការងារជាសំណង់ចឹងទៅ។គ្រាន់តែជា..

កៈ ចុះគាត់ទាំងអស់គ្នានឹងមានក្រុមគ្រួសារអស់ហើយឬនៅអ៊ុំ?

ខៈ ជីវៈភាពក្នុងក្រុមគ្រួសារនឹងវាមិនទៅបានជាគ្រាប់គ្រាន់ផងនឹង។
កូនខ្ញុំនឹងវានៅមិនទាន់បានរៀបការនឹងមាន៣នាក់ទៀតខ្ញុំ។

កៈ ចាសហឺស ហើយទៅពួកគាត់ដូចជា តើឥឡូវនឹងអ៊ុំមានចៅហើយឬនៅ?

ខៈ ចៅមានបាន៨នាក់ហើយ។

កៈ ៨នាក់ហើយ។

ខៈ ចាស

កៈ ហើយអ៊ុំមិនទាន់បានរៀបការកូនអ៊ុំមានកូនណាខ្លះដែល?

ខៈ ចាស?

កៈ កូនរបស់អ៊ុំដែលមិនទាន់បានរៀបការណា?

ខៈ នៅមានកូន៣នាក់ទៀតមានកូនបងគេមួយ កូនសំណាមួយ កូនសារៈ១ នឹងកូនចាន់បូរមី១។

កៈ ហឺចាសអ៊ុំ ហើយអ៊ុំមានបានសិក្សាដល់កំរិតណាដែរ?

ខៈ
ខ្ញុំនឹងវាបានបន្តិចបន្តួចទេវាបានតែប៉ុណ្ណឹងកាលនឹងខ្ញុំបានរៀនបានត្រឹមតែថ្នាក់ទី១២យើងនឹងព្រោះកាលពីជំនាន់នៅពីសង្គមមកនឹង។

កៈ ចឹងបើគិតកាលពីជំនាន់ពីទី១២មកនឹងកាលនឹងគឺបានឡើងហើយអ៊ុំ?

ខៈ ហឺសៗៗ

កៈ ហឺសៗ

ខៈ ថ្នាក់ទី១ឥឡូវនឹងសោះនឹងហាហ

កៈ
កាលនឹងគេបានបង្រៀនអ៊ុំយ៉ាងម៉េចខ្លះទោកាលនៅក្នុងជំនាន់នឹងតើគេបានធ្វើការបង្រៀនអ៊ុំបានយ៉ាងណាខ្លះដែរអ៊ុំពេលដែលអ៊ុំបានរៀនត្រឹមថ្នាក់ទី១២នឹង?

ខៈ ហឺស
កាលនឹងអ៊ុំនៅជាក្មេងខ្មាងដូចជាពេលនឹងអ៊ុំមិនសូវបានជាចាំទេកាលនឹងព្រោះអីអ៊ុំបានភ្លេចវាអស់ទៅហើយ។

កៈ ហឺៗ

ខៈ គ្មានបានសូវជាចេះអីនោះទេ។

កៈ ចាស តែដូចជាអ៊ុំអាចនឹងបានមើលអីបានអាចអានដាច់អីដែរតើនូវអក្សរខ្មែររបស់យើង?

ខៈ អត់ឥឡូវនឹងសមភ្នែកនឹងវាឡើងងងឹតទៀតនឹងវាមើលអីមិនបានឃើញតែម្តងឡើយ។

កៈ ចាសអ៊ុំហើយចឹងកាលនឹងអ៊ុំបានរៀននៅក្នុងសាលាណាដែរ?

ខៈ ខ្ញុំបានរៀននឹងនៅឯអំឡុកឯនោះនៅក្នុងស្រុកអង្គបុរីឯនោះ។

កៈ ហើយចុះអ៊ុំឈ្មោះសាលាអីនឹងមានឈ្មោះអ្វីដែរ?

ខៈ នៅក្នុងវត្តអំលក ។

កៈ នៅក្នុងវត្តទេចឹងអ៊ុំណ៎?

ខៈ ចាស!!

កៈ ហើយចឹងនៅក្នុងទីរួមស្រុកនៅក្នុងខេត្តនៅក្នុងស្រុកឃុំរបស់អ៊ុំផ្ទាល់ណ៎អ៊ុំណ៎?

ខៈ នៅអើយនៅក្នុងខេត្តតាកែវដែលប៉ុន្តែវាខុសខេត្តតំបន់គ្នានៅក្នុងស្រុកអង្គបុរី ។

កៈ អូនៅក្នុងស្រុកខុសគ្នា។

ខៈ ឥឡូវនឹងគេបានប្តូរឈ្មោះទៀតហើយឥឡូវនឹង។

កៈ អ៊ុំសាលារៀននឹងនៅខុសស្រុកគ្នាឬក៏នៅក្នុងស្រុកជាមួយនឹងគ្នា?

ខៈ
កាលនឹងនៅជាមួយនឹងគ្នាដែលឥឡូវនឹងខ្ញុំបានមានប្តីចឹងទៅក៏បានមកនៅក្នុងស្រុកជាមួយនឹងប្តីខ្ញុំនឹងចឹងទៅ។

កៈ អូ!

ខៈ តាំងពីនៅក្នុងឆ្នាំ១៩៧៦មកម៉េច។

កៈ អូ!

ខៈ នៅក្នុងខែ១នឹងមក។

កៈ ចាសហើយកាលដែលអ៊ុំទៅរៀននឹងអ៊ុំមានបានទៅដោយធ្វើការជិះកង់ឬក៏ដើរឬក៏អ្វីដែរអ៊ុំ?

ខៈ ហឺសបើនិយាយពីប្រវត្តិរៀននឹងវិញនឹងនិយាយថាវាឡើងកំសត់នោះពេកហើយ
កាលនឹងមានតែអាវពាក់នឹងតែ១កំផ្លែនោះទេ
កាលនឹងមកពីរៀនវិញនឹងធ្វើការគ្ចកខោអាវហើយពេលបានមកពីញ៉ាំបាយវិញនឹងបានហាល
អាវទៅអោយវាបានស្ងួត។
កាលនឹងមានបានកង់អីឯណាបើនិយាយពីលុយនឹងវាគ្មានអីសំរាប់នឹងចាយផងពីព្រឹកព្រលឹម
ឡើងនឹង។

កៈ ចាស!

ខៈ
វាឡើងកំសត់កំរចឹងអីនឹងវាមិនមែនជាដូចសម័យក្មេងឥឡូវនឹងវាមានជំទៅម៉ូតូហើយនឹងអោ
យវាបានជិះទៅរៀននឹងវាមិនរៀនទៀតណ៎។

កៈ ហឺសចាសនិយាយទៅកាលនឹងអ៊ុំមានការតស៊ូក្នុងជីវតណាស់កាលនឹង។

ខៈ ហឺកាលនឹងវាឡើងយ៉ាប់មែនទែនតែម្តងនឹង។

កៈ ហឺចាស!

ខៈ
ហើយខ្ញុំនឹងបងប្អូនរបស់ខ្ញុំនឹងក៏ច្រើនដែលនឹងហើយមានសុទ្ធប្រុសដែលនឹងខ្សត់ស្រីដែលនឹង
ព្រោះក្រចឹងហើយកាលនឹងវាមានសូវបានរៀនអី។

កៈ អូចាស!

ខៈ ហឺការងារកាលនឹងវារាងច្រើន។

កៈ ហឺ!

ខៈ កាលនឹងមានបានធ្វើស្រូវប្រាំអីចឹងទៅកាលនឹង។

កៈ ហឺហើយចឹងកាលនឹងអ៊ុំមានបងនឹងប្អូនបានប៉ុន្មាននាក់ដែល?

ខ៖
ខ្ញុំមានបងប្អូននឹងវាមាន១០នាក់ឯណោះប៉ុន្តែពួកគាត់មានខ្លះទៅបានស្លាប់អស់ទៅហើយ។

ក៖ ចឹងបងប្អូនរបស់អ៊ុំស្រីអត់មាននៅសល់១នាក់អីទេអ៊ុំណំដែលមានរស់មកដល់សព្វថ្ងៃនេះ?

ខ៖
នូវមាន៦នាក់នឹងដែលនឹងប៉ុន្តែគេបានដើររកស៊ីទៅនេះទៅនោះនៅស្រុកគេអស់ហើយមានទៅប្រទេសថៃអីនឹងគេទៅអស់ហើយ។

ក៖
ចឹងបងប្អូនរបស់អ៊ុំទាំងអស់មានប៉ុន្មានសរុបនឹងមានតែនាក់នឹងទេណំអ៊ុំ?ហើយគាត់សព្វថ្ងៃនឹងមានជីវិតបាន៦នាក់ចឹងហើយពេលនឹងអ៊ុំមានបងប្អូនដែលគាត់នៅរស់មកដល់សព្វថ្ងៃនឹងមានសល់ចំនួន២នាក់ណំអ៊ុំណំ?

ខ៖ ចាស

ក៖
ចាសហើយចុះបងប្អូនរបស់អ៊ុំស្រីទាំង៨នាក់នឹងដែលមានគ្នាទាំងអស់មាន៨នាក់នឹងតើពួកគាត់មានឈ្មោះអ្វីខ្លះដែរទៅអ៊ុំ?ហើយបងប្អូនអ៊ុំដែលនៅមានជីវិតទាំងនាក់នឹងតើពួកគាត់មានឈ្មោះអ្វីដែរ?អ៊ុំបាននៅចាំដែរឬទេ?

ខ៖
កាលនឹងនៅក្មេងៗនឹងហើយពេលអ្នកដែលបានស្លាប់ទៅបាត់នឹងគេមានអាយុនៅតូចៗនឹងគេនឹងនៅតូចៗនឹងហើយអាយុវិញនឹងខ្លះទៅទឹមបាន១ខួបជាងអីនឹងគេនៅតូចៗនឹងបានស្លាប់ទៅ។

ក៖ ហឺហើយចុះអ៊ុំកាលដែលនៅក្នុងជំនាន់អាពតនឹងអ៊ុំមានអាយុបានប៉ុន្មានឆ្នាំដែរ?

ខ៖
ហឺកាលនឹងនៅក្នុងជំនាន់អាពមកនឹងកាលនឹងមិនបានដឹងថានៅអាយុបានប៉ុន្មានឆ្នាំទៀតនឹងណាមកដល់ឥឡូវ។ វារាងបានភ្លេចខ្លះទៅកាលនឹងនៅនឹកមិនបានចាំនោះទេ។

កៈ
ចឹងកាលនឹងអ៊ុំកាលនៅក្នុងជំនាន់អាពតនឹងអ៊ុំមានវ័យបានប៉ុន្មានដែរដូចជាពេលនឹងអ៊ុំមានវ័យនៅរាងក្មេងៗឬក៏ការនឹងអ៊ុំបានចូលទៅក្នុងកងកុមារអីចឹងណាអ៊ុំ?

ខៈ ហឺកាលនឹងអ៊ុំមានបានអាយុនឹងប្រហែលជា១៨ឆ្នាំអីនឹងកាលនឹង។

កៈ
ចាសចឹងកាលនឹងអ៊ុំមាននៅក្នុងពេញវ័យដែលនឹងកាលនឹងនោះចឹង។ព្រោះអីកាលនឹងបើអ៊ុំស្រីមានអាយុប្រហែលជាបានប៉ុណ្ណឹងចឹងមានតែអ៊ុំនៅក្នុងកងនារីហើយចឹងកាលនឹង?

ខៈ កាលនឹងអ៊ុំកំពុងតែបានធ្វើការពេញទំហឹងហើយកាលនឹងនោះ។

កៈ ចាសអ៊ុំហើយចុះអ៊ុំចំណែកឯឪពុកម្ដាយរបស់អ៊ុំវិញតើពួកគាត់មានឈ្មោះអ្វីដែរទៅអ៊ុំ?

ខៈ ឪពុកម្ដាយរបស់ខ្ញុំ ឪរបស់ខ្ញុំនឹងគាត់មានីឈ្មោះថាសុខ

កៈ ចាស!

ខៈ ម្ដាយឈ្មោះកាន។

កៈ
ចាសហើយចុះពួកគាត់មានឈ្មោះពេញដូចជាមានឈ្មោះនាមត្រកូលអីនឹងតើអ៊ុំមានបានចាំដែរឬទេ?

ខៈ នាមត្រកូលរបស់គាត់ហែស?

កៈ ចាស!

ខៈ នាមត្រកូលរបស់គាត់នឹង
អឺឪពុករបស់ខ្ញុំនឹងខ្ញុំមិនបានដឹងថាគាត់បានដាក់នាមត្រកូលយ៉ាងម៉េចផងព្រោះអីកាលនឹងខ្ញុំមិនបានទៅសួរគាត់ផងនោះ។

កៈ ហឺចាស!

ខៈ នឹងហើយ!

ក៖ ហើយចឹងអ៊ុំចឹងនាមត្រកូលរបស់ឪពុកនឹងម្ដាយរបស់អ៊ុំអី?

ខ៖ ចាស!

ក៖ ឈ្មោះនាមត្រកូលរបស់ពួកគាត់ចឹងអ៊ុំមិនបានចាំទេ?

ខ៖ កាលនឹងខ្ញុំមិនបានដឹងថាគាត់នឹងមានដាក់ឈ្មោះអីនឹងទេ។

ក៖ អូចាស!

ខ៖ កាលនឹងគាត់បានដាក់នឹងច្រើនតែលោកតាទូតអីចឹង។

ក៖ ចាសហើយចុះសព្វថ្ងៃនឹងឪពុកម្ដាយរបស់អ៊ុំនឹងនៅមានជីវិតដែលឬទេ?

ខ៖ចាសគាត់នៅមានជីវិត។

ក៖ ចាស!

ខ៖ គាត់មានអាយុប្រហែលជាបាន៨០ឆ្នាំជាងហើយ។

ក៖ គាត់បាននៅក្នុងបន្ទុកជាមួយនឹងអ៊ុំ?ឬក៏គាត់បាននៅផ្សេងពីអ៊ុំ?

ខ៖ អត់ទេគាត់បានទៅនៅឯស្រុកផ្សេង។

ក៖
អូចាសហើយចឹងចុះបងប្អូនរបស់អ៊ុំស្រីនឹងសព្វថ្ងៃដែលពួកគាត់នៅមានជីវិតនឹងតើពួកគាត់មានមុខរបរជាអ្វីដែរ?

ខ៖ អូគាត់ទាំងអស់គ្នានឹងទៅនៅឯស្រុកឆ្ងាយឯនោះនឹងគាត់បានទៅរកស៊ីស៊ីឈ្នួលគេនឹង។

ក៖ ចាសចឹងអ៊ុំមានការស្នាក់នៅនឹងមានទីលំនៅនៅឆ្ងាយៗពីគ្នាន់អ៊ុំ?

ខ៖ ចាស!

ក៖ ចាស!

ខ៖ ខ្ញុំបានធ្វើចំការហើយធ្វើការស៊ីឈ្នួលគេចឹងទៅ។

កៈ ចឹងអ៊ុំបាននឹងពួកគាត់ហើយចឹង។

ខៈ ចាស?

កៈ
ចឹងអ៊ុំមានការនឹងកពួកគាត់ហើយចឹងនោះ?ព្រោះអីពួកគាត់ទៅនៅធ្វើការងារនៅឆ្ងាយៗពីគ្នាចឹង។

ខៈ
ចេះតែនឹងចឹងដែលនឹងព្រោះអីពេលខ្លះនឹងគេបានតេមកចឹងហើយក៏បានធ្វើការនិយាយគ្នាបានខ្លះចឹងដែរទៅ។

កៈ
ចុះអ៊ុំចឹងតើអ៊ុំធ្វើយ៉ាងម៉េចខ្លះទៅដូចជាពេលដែលអ៊ុំបានជួបគ្នានៅពេលមានបុណ្យទានអីចឹងទៅហើយអ៊ុំក៏បានទៅលេងគ្នាចឹងមែន?

ខៈ
អត់ទេមិនបានទៅទេព្រោះអីនឹងខ្ញុំឯណាបានទៅរកប្អូនឯណាទៅបានឃើញបើខ្ញុំនឹងវាឧស្សាហ៍បានឈឺច្រើននឹងចេះនឹង។

កៈ ចាសហឹស

ខៈ ប៉ុន្តែនឹងវាចេះតែវិល ពេលដែលបានងើបឡើងនឹងវាចេះតែវិលចឹង។

កៈ ចឹងអ៊ុំឥឡូវនឹងមានឈឺច្រើន?

ខៈ វាចេះតែវិលមុខនឹងចឹងណា
ហើយបើថាវាបានវិលមុខហើយនឹងវាធ្វើទុក្ខដល់បេះដូងនឹងឡើងដុកដាក់បេះដូងនឹងយើងភ័យៗហើយបានបែកញើសជោកហើយបានបែកញើសឡើងត្រជាក់ព្រោះអីបានបែកញើសត្រជាក់ហើយនឹងវាបានចាប់ផ្តើមឡើងក្អួតហើយ។(មានសំលេងម៉ូតូជិះកាត់នឹង)
ពេលដែលបានឈឺម្តងៗនឹងខ្ញុំបានដាក់សារ៉ូមហើយបានដាក់សារ៉ូមឡើង២ទៅ៣ផ្លោកហើយនឹងហើយមានពេទ្រគេបានចាក់សារ៉ូមបានហើយគេបានចុកថ្នាំបាន៩ទៅ១០ម្ទុលអីចឹងទៅ។

កៈ ហឺ

ខៈ
ហើយបានងើបទៅនឹងបានប្រហែលតែ២ទៅ៣ខែអីនឹងក៏បានឈឺឡើងវិញចឹងអីទៅទៀតចឹងទៅ។

កៈ ចាសហឹសអ៊ុំអោយ។

ខៈ នឹង!

កៈ
ហឺពេលនឹងដូចថាជាជំងឺនឹងវាចេះបានតែមកចឹងទៅណាអាជំងឺនឹងនោះវាចេះតែឈឺតៗគ្នា។

ខៈ
នឹងហើយវាចេះតែឈឺព្រោះអីនឹងដោយសារតែខ្ញុំនឹងវារាងដូចថាជាចាស់ណាស់ទៅហើយចឹងហើយបានថាវាចេះតែមានជំងឺឈឺតៗគ្នានឹងណា។

កៈ ហឺ

ខៈ ហើយនឹងវាចេះតែបាយវាមិនបានហើយវាចេះតែសំរានវាមិនបានលក់នឹងណា។

កៈ ចាសចឹងអ៊ុំត្រូវតែចេះថែរក្សាសុខភាពដោយខ្លួនឯង

ខៈ នឹងហើយ!

កៈ ព្រោះអីអ៊ុំបានដឹងថាអ៊ុំចាស់ហើយណាអ៊ុំណា

ខៈ ចាស!!

កៈ សូមអ៊ុំខំប្រឹងញុំាហើយ

ខៈ
ហើយកានឹងឥឡូវនឹងក៏ខ្ញុំវាមិនចង់ទៅដែលនឹងព្រោះអីដូចថាពេលនឹងជាពេលមិនបានទៅរមិនកើតទេព្រោះអីវាការក្បួយឯងនឹងបង្កើត។

កៈ ចាសចឹងអ៊ុំបានមកថ្ងៃនឹងអ៊ុំបានមកដើម្បីនឹងទៅការក្មួយនោះទេហ៎?

ខៈ នឹងហើយទៅការគេណ៎នៅឯស្រុកគេណ៎នៅដល់ខេត្តកំពង់ចាមឯណ៎។

កៈ ចាសត្រូវជាក្មួយណ៎អ៊ុំណែស?

ខៈ ត្រូវជាក្មួយ

កៈ ហឺចឹងអ៊ុំខាងស្រីឬខាងប្រុស?

ខៈ ខាងស្រី។

កៈ ហេសៗចឹងខាងចឹងអ៊ុំជិតទេចឹងហោះហេសៗបើសិនជានៅឆ្ងាយក៏ត្រូវតែទៅដែល។

ខៈ ចាស!

កៈ ក្មួយស្រីផង

ខៈ ហើយតារបស់ខ្ញុំនឹងគាត់ថាមិនទៅទេព្រោះអីផ្លូវនឹងវានៅឆ្ងាយ។

កៈ ហឺ!

ខៈ គាត់ថាមិនចង់អោយយើងទៅជាមួយ។

កៈ ចាស!

ខៈ
ចាសប៉ុន្តែដល់ហើយទៅបានអោយមីបងនឹងគេបានទៅដែលចឹងទៅក៏បានទៅជាមួយនឹងគ្នា
បានគ្នា៣នាក់អីដែរ។

កៈ ចាសអ៊ុំ ហើយអ៊ុំសព្វថ្ងៃនេះដូចជាអ៊ុំមានមុខរបជាអ្វីដែរទៅអ៊ុំ?

ខៈ ខ្ញុំធ្វើតែស្រែ។

កៈ ចឹងការពីមុខមកនឹងអ៊ុំបានធ្វើតែស្រែទេ?

ខៈ ចាសកាលពីមុនមកនឹងខ្ញុំបានធ្វើតែស្រែហើយឥឡូវនឹងក៏បានធ្វើតែស្រែដែល។

កៈ
ចាសចឹងអ៊ុំមានបទពិសោធន៍ច្រើនឆ្នាំហើយចឹងបទពិសោធន៍ច្រើនហើយចឹងតាំងពីមុននឹងរហូតមកដល់ឥឡូវនឹងបានប៉ុន្មានឆ្នាំហើយនឹងចឹងប្រហែលជា២០ទៅ៣០ជាងហើយណោអ៊ុំព្រោះអីតាំងពីបានដាច់សម័យជំនាន់អាពតមកម៉េច។

ខៈ ចាស!!

កៈ ចាសចឹងអ៊ុំមិនដែលបានប្តូរសោះឡើយនៅមុខរបរនឹង?

ខៈ
មិនដឹងជាបានប្តូរទៅណានោះទេបើយើងនឹងជាអ្នកក្រហើយខ្សត់ចឹងមិនដឹងថានឹងចង់ប្តូរទៅណានោះទេ។

កៈ ចុះអ៊ុំមានដីទេ

ខៈ មានទៅដើមទុនឯណាសំរាប់ទៅរកនឹងមានតែដើមទុនវាតែបន្តិចបន្តួចនឹង។

កៈ ចុះអ៊ុំមានដីដែរឬទេ?

ខៈ មានដីតែបន្តិចបន្តួចសំរាប់នឹងធ្វើស្រែសំរាប់នឹងយកទៅហូបនឹង។

កៈ ចឹងអ៊ុំមិនមានដើមទុននោះទេតែអ៊ុំនៅមានដី។

ខៈ នឹងហើយនៅសំរាប់ធ្វើស្រែនឹងនឹងហើយចុះដីយើងដូចថា

កៈ ដីកេរ្តិ៍

ខៈ
នឹងហើយដូចថាដីកេរ្តិ៍បាននៅសល់ពីជីដូនជីតាមកនឹងដែលពីកេរ្តិ៍តំណែលដែលបានបែកចែកមកបន្តិចម្នាក់នឹង។

កៈ ចាសត្រូវហើយអ៊ុំ

ខៈ នឹងហើយដីនឹងសំរាប់អោយយើងធ្វើសំរាប់នឹងហូបបានបន្តិចម្នាក់ចឹងទៅ។

កៈ ចាសត្រូវហើយអ៊ុំព្រោះអីដីកេរ្តិ៍នឹងសំរាប់ទុកអោយកូនចៅរបស់អ៊ុំនឹងណាក្រោយទៀត។

ខៈ នឹងហើយចឹងទៅកាលនឹងបានច្រើនអីទៀត។

កៈ ចុះអ៊ុំបានមានប៉ុន្មានហិតាដែលអ៊ុំ?

ខៈ ចាសអីគេក្មួយ?

កៈ ដីដែលអ៊ុំមាន?

(មានសំលេងទូរសព័ពោទ៍)

ខៈ ហឺដីនឹងវាមានតែបន្តិចដែលទេវាមិនមានទៅច្រើននោះទេដីនឹងនោះ។

កៈ ហឺ!

ខៈ ប្រហែលជាបាន១ហិតាជាងអីនឹង។

កៈ
អូចឹងតែប៉ុណ្ណឹងទេន៎អ៊ុំហើយចឹងតើអ៊ុំធ្វើស្រែចំការនឹងតែសំរាប់ដី១ហិតានឹងឬក៏អ៊ុំមានបានទៅជួលគេបន្ថែមទៀត?

ខៈ អ៊ុំអត់មានបានជួលគេផង។

កៈ អត់មានជួលគេទេអ៊ុំ?

ខៈ អត់នឹងអត់មានបានទៅជួលដីគេសំរាប់យកមកធ្វើស្រែបន្ថែមទៀតផងនឹង។

កៈ ចឹងអ៊ុំបានធ្វើតែដីសំរាប់តែក្នុង១ហិចនឹង។

ខៈ នឹងហើយធ្វើសំរាប់តែចំនួនដី១ហិចនឹង
ហើយក៏បានចែកអោយទៅកូននឹងខ្លះចឹងទៅហើយកូននឹងគេមិនបានមកធ្វើទេគេបានតែផ្ញើតែលុយអោយយកមកនឹងទេ។

កៈ ហឺ!

ខ៖ យើងនឹងបានជួលគេដែលបានជួលគេសំរាប់អោយគេនឹងព្រោះចឹងទៅ។

ក៖ ចាសចឹងក្នុង១ឆ្នាំនឹងអ៊ុំបានរកប្រាក់ចំណូលបានប៉ុន្មានដែរ?

ខ៖ ហឺរកនឹងរកគ្រាន់តែបានតិចតួចទេ
បើថាបើរកសព្វថ្ងៃនឹងបើថាអោយសល់នឹងវាគ្មានបានទៅសល់នោះទេព្រោះអីរកបាននឹងបាន
តែត្រឹមថាទៅសំរាប់នឹងយកទៅចង់ដៃបុណ្យអីគេវិញនឹងហើយនឹងការតែគេនឹង។

ក៖ ហឺស១

ខ៖ គ្មានបានសល់គ្មានបានអីនោះទេ។

ក៖ ដូចជាបានសល់នៅខ្ទង់ពាន់អីទេអ៊ុំ?

ខ៖ ហឺអត់ទេវាមិនទៅបានរកអីដល់ត្រឹមពាន់នោះទេលោកអើយ។

ក៖ អ៊ុំនៅក្នុង១ឆ្នាំវាមិនមែននៅក្នុង១ខែនោះទេ?

ខ៖ អត់ទេមិនរកបានទេ។

ក៖ ចាសចឹងអ៊ុំនៅក្នុង១ឆ្នាំនឹងតើអ៊ុំអាចនឹងធ្វើស្រែស្រូវនឹងបាន២ដងដែរឬទេអ៊ុំ?

ខ៖ អត់ទេខ្ញុំបានធ្វើនឹងតែចំនួនតែ១ដងនឹងទេ។

ក៖ អូអ៊ុំបានធ្វើតែ១ដង់ទេ។

ខ៖
ព្រោះអីបើសិនជាយើងបានធ្វើវាច្រើនដងពេកនឹងវាយ៉ាប់តែខ្លួនឯងនឹងព្រោះអីវាយ៉ាបពេកនឹង
វាធ្វើតែបាបដល់ខ្លួនឯង។

ក៖
ចឹងអ៊ុំបើសិនជាធម្មតានឹងតើអ៊ុំអាចរកបានចំណូលបានប៉ុន្មានដែរនៅពេលដែលបានប្រមូលផ
លម្តងៗ?

ខ៖
ហឺបានតែ៥០ទៅ៦០ស្បោងនឹងវាបានគ្រាន់តែបានហូបសំរាប់នឹងជីវៈភាពសំរាប់នឹងគ្រួសារនឹង។

ក៖ ចាសៗ!

ខ៖ នឹងហើយ

ក៖ ហើយអ៊ុំអឺ......

ខ៖ គ្រាន់តែយើងនឹងវាមិនបានទៅទិញលក់ដូរអីដូចគេ។

ក៖
ចាសអ៊ុំហើយទាក់ទង់នឹងការនៅក្នុងសម័យកាលពីមុនមកនឹងកាលនៅក្នុងជំនាន់ពពតនឹងគេបានធ្វើការជំលៀសអ៊ុំទៅណាដែលអ៊ុំ?

ខ៖ អត់ អត់មានគេធ្វើការជំលៀសនឹងទៅណាផង។

ក៖ អូចឹងអ៊ុំចឹងកាលនឹងអ៊ុំនៅស្រុកកំណើតរបស់ខ្លួនឯងតែម្តង។

ខ៖ ចាសនៅស្រុក។

ក៖ ចុះគេបាប្រើអ៊ុំអោយធ្វើអ្វីខ្លះដែរកាលនឹង?

ខ៖ មានធ្វើអីនោះទេកាលនឹងគេបានប្រើអោយទៅធ្វើស្រែនឹងដូចតែគ្នានឹង។

ក៖
ចឹងហើយថាកាលនឹងអ៊ុំបានធ្វើស្រែនឹងហើយមកដល់ឥឡូវនឹងអ៊ុំក៏បានយកជំនាញនឹងមកធ្វើវាទៀត។

ខ៖ ចាសតែដូចជាអត់មានជំនាញអីសំរាប់នឹងធ្វើនោះទេមានតែជំនាញធ្វើស្រែនឹង។ហឺសៗ

ក៖ ចាសតពីមុនមក

ខ៖
ហើយឥឡូវនឹងវាបានយ៉ាបទៀតនឹងវាមិនដូចទៅនឹងនៅឯសម័យសង្គមចាស់នោះទេព្រោះអីកាលនៅក្នុងពីសម័យនៅឯសង្គមចាស់យើងនឹងមានតែការទៅប្រមូលស្លឹកឈើព្រៃអីសំរាប់យកទៅចាក់នឹងក៏នៅតែមើលឃើញស្រូវនឹងបានល្អតែមកដល់ឥឡូវនឹងយើងបានបាច់ទាំងដល់ជីទៀតឯណោះក៏នៅតែវាមិនបានល្អ។

ក៖ ចាស

ខ៖ នៅតែមិនបានស្រួលនឹងនៅមានដង្កូវវាឡើងស៊ីស្លឹក
មានប្រាលស៊ីកាច់ហើយមានអាស៊ីគល់ទៅវាបានងាប់ចឹងទៀត
យ៉ាបនឹងធ្វើណាស់ស្រែឥឡូវនឹងដល់តែពេលវាបានជឿនលឿនពេក។

ក៖ ចាស!

ខ៖
ពេលដែលបានធ្វើបានមកនឹងបានតែទៅអោយគេវិញបានអោយទៅថ្នាំសំលាប់សត្វមានដង្កូវអីនឹងវិញ។

ក៖ ចាសហើស

ខ៖ ហឺ!

ក៖ ដោយសារតែអ៊ុំបានទិញវាមកនឹងវាថ្លៃពេកណ៎អ៊ុំណ៎?

ខ៖ ចាសនឹងហើយ

ក៖ ចាសអ៊ុំចឹងខ្ញុំមាន...

(សំលេងម៉ូតូលោកតាប្តីលោកយាយមកដល់ក្នុងវត្ត)

ខ៖ ន៎គាត់បានមកហើយតាខ្ញុំន៎

កៈ
អូលោកតាបានមកហើយចឹងតើខ្ញុំអាចនឹងសុំពេលអ៊ុំបន្តិចតើបានដែរឬទេគ្រាន់តែសុំលោកតាបានចាំប្រហែលជា៥នាទីអីដើម្បីនឹងធ្វើការបង្ហើយនឹងធ្វើការសំភាសន៍ណាអ៊ុំ?

ខៈ
មិនដឹងថានឹងត្រូវសំភាសន៏អីនឹងទៀតផងនឹងដូចជាមិនដឹងថាមានបញ្ហាអីទៀតផងនឹងហាហា

កៈ
ខ្ញុំចង់សួរអ៊ុំកាលពីក្នុងសម័យពពតមកនឹងតើអ៊ុំមានបានចង់ចាំថាកាលនឹងគេបានធ្លាប់ធ្វើបាបអ៊ុំហើយទៅអ៊ុំមានការចង់ចាំអ្វីខ្លះទៅកាលនៅក្នុងសម័យនឹង?

ខៈ ហេសកាលនឹងនៅក្នុងសម័យពពតនឹងគេដូចជាអត់មានធ្វើបាបអីទេខ្ញុំនឹង គ្រាន់តែពេលនឹងគេគ្រាន់តែថាគេបានអោយយើងនឹងទៅជីកដីជីអាយអីចឹងទៅកាលនឹងនោះព្រោះអីកាលនឹងខ្ញុំដូចជាបាននៅក្មេងដែរនឹងកាលនៅក្នុងសម័យនោះនឹងខ្ញុំវាមិនទាន់បាននឹងធ្វើបាបអីនឹងនោះទេកាលនឹងនោះចាស។

កៈ អូកាលនឹងអ៊ុំបានអាយុ១៨ឆ្នាំហើយចឹង។

ខៈ ចាសការនឹងខ្ញុំនឹងវានៅវាងមាឌវាងល្អិតដែលនឹង។

កៈ ហឹសៗៗ

ខៈ ចឹងហើយបានជាគេនឹងមិនបានអោយទៅប្រើអីវឹកវីនអីនោះទេកាលនឹងនោះ។

កៈ ចឹងកាលនឹងគេស្រួលដែលអ៊ុំណុំ?

ខៈ ចាស!

កៈ គេមិនមានបានធ្វើបាបអីដល់អ៊ុំទេកាលនឹង?

ខៈ
អត់ទេកាលនឹងវានៅក្មេងៗនឹងដល់ចឹងទៅគេមិនបាននឹងធ្វើបាបយើងអីនោះទេកាលនឹងនោះគេមិនបានធ្វើបាបអីនោះទេគេយកយើងបានហូបទៅត្រឹមត្រូវនឹង។

កៈ ចឹងកាលនឹងគេបានអោយបាយយើងនឹងគេមិនបានអោយបបរយើងទេកាលនឹង?

ខៈ
វាមានថ្ងៃណាដែលបានដាច់ពេលអីនឹងចឹងគេក៏បានអោយបបរទៅហើយបើថាពេលនឹងយើងនៅរាងក្មេងៗដែលនឹងចឹងយើងនៅកន្លែងទៅគេបានអោយបាយយើងអីដែលចឹងទៅហើយបើជាថ្ងៃណាគេបានអោយបបរចឹងទៅគេអោយបបរនឹងចឹងយើងក៏បានហូបទៅហើយបើថាថ្ងៃណាគេមានអង្កគេមានអីចឹងគេក៏អោយជាបាយអីចឹងទៅ។

កៈ ហឺ

ខៈ
វាមិនទៅជាទៀងអីដែលនឹងហើយបើថាយើងទៅធ្វើការងារជីកដីជីកអីចឹងទៅគេបានដាក់ទៅហើយមានបបរនឹងវារាងបានខាប់អីតិចដែលបានខាប់អីនឹងតិចទៅ ។

កៈ ចាស
ហើយទៅកាលនឹងអ៊ុំមានបាននឹងធ្លាប់បានមើលឃើញអាពតមានបានយកមនុស្សទៅសំលាប់ចោលនៅនឹងភ្នែកដែលឬទេ?

ខៈ អត់ទេអត់ដែរនោះទេ។អត់ដែលបានមើលឃើញតែម្តង។

កៈ អូចឹងអ៊ុំមិនដែលបានឃើញទេ។

ខៈ អត់ដែរទេ

កៈ អូអ៊ុំ

ខៈ
ពេលនឹងបានលឺត្រឹមបានថាពេលនឹងគេបានធ្វើការជំលៀសពួកគាត់១៧មេសាពីភ្នំពេញយើងនឹងទៅដែលគេថាយកពួកគាត់ទៅវៃចោលទៅ
ហើយពេលនឹងបានលឺតែចឹងទៅមិនបានដឹងថាគេបានយកពួកគាត់ទៅដល់ពេលណាពេលណានោះទេខ្ញុំវាអត់បាននឹងដឹងទេ។

ក៖
ចាសហើយទៅកាលនឹងគេបានជំលៀសអ៊ុំទៅនឹងទាំងគ្រួសារឬក៏យ៉ាងណាដែលកាលនឹង?

ខ៖
អត់បានដឹងកាលនឹងព្រោះអីកាលនឹងគេថាយកទៅនឹងពីភ្នំពេញយើងនឹងទៅតែមិនបានដឹងថាគេនឹងយកទៅជំលៀសនឹងទាំងគ្រួសារឬក៏យ៉ាងណានោះទេកាលនឹងអត់បានដឹងដែលនឹង។

ក៖
ចាសហើយចុះកាលជំលៀសនឹងគេបានធ្វើការជំលៀសអ៊ុំស្រីផ្ទាល់ទាំងគ្រួសាររបស់អ៊ុំឬក៏គេជំលៀសអ៊ុំអោយបែកគ្នា?

ខ៖ អត់ទេកាលនឹងខ្ញុំអត់មានបានបែកអីផង។

ក៖ គេបានគេធ្វើការជំលៀសអ៊ុំនឹងគ្រួសារទាំងអស់គ្នានឹងនៅនឹងកន្លែងធ្វើការនឹងតែម្តង?

ខ៖ ចាស

ក៖
ចាសហើយខ្ញុំសួរអ៊ុំទៅនឹងតើអ្វីដែលអ៊ុំបានចង់ចាំជាងគេនៅក្នុងសម័យពពតនឹងណាអ៊ុំតើអ៊ុំមានការចង់ចាំអ្វីជាងគេដែរ?

ខ៖ អត់ដូចជាអត់បានចាំទេកាលនឹង។

(មានសំលេងលោកបានចូលមកកោះជួងដើម្បីនឹងធ្វើការហៅព្រះសង្ឃអោយចូលទៅឆានបាយនៅក្នុងកុតជុំព្រះអង្គ)តឹងៗៗៗៗ

ខ៖ កាលនឹងអត់បានចាំនោះទេកាលនៅក្នុងជំនាន់ពពតនោះនឹង។

(តឹងៗៗៗៗ)

កៈ
ចាសចឹងនេះម៉េចនឹងគឺជាសំលេងជួងដែលព្រះសង្ឃទ្រង់បានដល់ពេលដែលត្រូវឆាន់ហើយអ៊ុំនេស?

ខៈនឹងហើយលោកកំពុងតែវេសហើយនឹង។

កៈ ចាសហើយទៅលោតាអ៊ុំប្រុសនឹងគាត់ត្រូវជាអាចារ្យវត្តនៅនេះតែម្តង?

ខៈ នឹងហើយគាត់កំពុងតែធ្វើការវេហើយនឹង។

កៈ ចាស
ចាសអ៊ុំហើយទៅខ្ញុំបានមើលឃើញថាគ្រួសាររបស់អ៊ុំស្រីមានសុភមង្គលណាស់មើលទៅទោះបីជាអ៊ុំប្រុសនឹងអ៊ុំស្រីត្រូវបានអាពតជាអ្នកដែលផ្សំផ្គុំអោយមែនតែមើលទៅអ៊ុំនៅតែស្រលាញ់គ្នារហូតមក។

ខៈ
ចាសអត់អីនោះទេអត់ដែលបាននឹងទាស់នឹងឈ្លោះគ្នាអីនោះទេព្រោះអីនឹងគាត់មកនេសតែបាត់ៗដែលនឹងហាហាហា

កៈ ហាហាហា

ខៈ ដូចជាពេលខ្លះទៅនឹងគាត់បានទៅក្នុងរយ
:ពេលបាន៩ទៅ១០ថ្ងៃអីចឹងទៅបានទៅមើលកូនចៅម្តងអីចឹងដែល។

កៈ ហឺ

ខៈ ហើយមានលុយអោយចៅចាយអីចឹងខ្លះទៅ។

កៈ ចាស!

ខៈ ហឺសហឺសៗ

កៈ
ហើយទៅអ៊ុំចង់និយាយថាអ៊ុំបាននៅកាលពីក្មេងហើយបានមកដល់ពេលឥឡូវនឹងអ៊ុំមានបានក្តីស្រមៃចង់ធ្វើអ្វីដែរឬទេអ៊ុំ?

ខៈ
មិនដឹងជាចង់ធ្វើអ្វីនោះទេអ៊ុំព្រោះអីដូចជាវានិងអស់លទ្ធិភាពបានធ្វើហើយមកដល់ពេលឥឡូវនឹង។ហឹសៗៗនៅតែផ្ទះនឹងហើយនៅបានចាំតែផ្ទះនឹងហើយ
ឥឡូវនឹងបាននៅមើលគោអីនឹងនៅឯនាយនៅឯអាយនឹងនៅបានធ្វើស្រែអីចឹងទៅ។

កៈ ចាស ហឹហើយចុះ...

ខៈ
ហើយបើតាខ្ញុំវិញនឹងគាត់បានជាអ្នកនៅក្នុងវត្តនឹងគាត់បាននៅនឹងតាំងពីក្នុងសម័យ១៩៧៩មក ពេលមុននឹងគាត់បានទៅនៅនឹងជាមួយនឹងលោកមាដែលគាត់មានឹងគាត់បានបួស
ដល់ពេលបានមកនៅជាមួយនឹងមាចឹងទៅហើយគាត់មានឹងបានសុគតចឹងទៅក៏បាននៅជាមួយនឹងក្មួយទៀតដែលត្រូវជាកូនរបស់លោកនឹង
ដល់ពេលហើយទៅក៏បានសឹកអស់ចឹងទៅហើយពេលនឹងបានចឹងទៅហើយក៏គាត់នឹងបានចេះតែនៅចឹងៗទៅរស់នៅនឹងទៅគ្មានបានទៅណាគាត់។

កៈ ចាស
ចឹងទាក់ទងនឹងក្រុមគ្រួសាររបស់អ៊ុំស្រីនឹងតែម្តង់នឹងអ៊ុំអត់ដែលមានបញ្ហាអ្វីនោះទេដូចជាអ៊ុំប្រុសគាត់បានធ្វើបាបអ៊ុំនឹងធ្វើអោយអ៊ុំពិបាកចិត្តអីទេ?

ខៈ អត់ទេ

កៈ អត់ដែលមានទេអ៊ុំ?

ខៈ អត់អីនោះទេអត់ដែលមាននោះទេ។

កៈ ចាសចឹងបានសុខសប្បាយមករហូត។

ខៈ ចាសបានសុខសប្បាយមក។

កៈ
ហើយទៅនៅក្នុងជិវិតរបស់អ៊ុំស្រីផ្ទាល់តើអ៊ុំមានធ្លាប់មានបញ្ហាឬក៏រឿងអីណាមួយដែលធ្វើអោយអ៊ុំមិនសប្បាយចិត្តឬក៏ធ្វើអោយលំបាកដែលវានឹងធ្វើអោយអ៊ុំបានចង់នឹងចាំវារហូតមកដល់ឥឡូវនេះ?

ខៈ
ហឹមានអាពេលដែលយើងនឹងបានមានជំងឺហើយនឹងចឹងហើយបានជាវានឹងដែលពេលយើងឈឺចឹងទៅវាបានធ្វើអោយយើងនឹងបានពិបាកចឹងទៅ
ពេលណាដែលឈឺចឹងទៅបានវាពិបាកចឹងទៅហើយកូនចៅនឹងវាបានយកយើងនឹងទៅពេទ្រទៅមលអីចឹងទៅ
ហើយបើថាពេលដែលដែលបានជានឹងវាបានជារាងបានស្រលះនៅក្នុងខ្លួនអីចឹងដែលទៅ។
បានដើរទៅនេះទៅនោះចឹងទៅវាបានរាងធូក្នុងអារម្មណ៍ចឹងដែលចឹងទៅ។

កៈ
ចាសត្រូវហើយអ៊ុំហើយចុះសំរាប់បទពិសោធន៏ជីវិតល្អៗរបស់អ៊ុំនៅក្នុងជីវិតរបស់អ៊ុំនឹងតើអ៊ុំមានដែលបានជួបនឹងមានដែលបានដឹងដែលឬទេដូចជាមានដែលបានជួបរឿងដែលធ្វើអោយអ៊ុំបាននឹកឃើញហើយនឹងធ្វើអោយបានសប្បាយចិត្តពេលដែលអ៊ុំបាននឹងឃើញ?

(មានសំលេងលោកសូត្រធម៍)

ខៈ អត់អត់មានថាដែលពិបាកអីដែលនឹងនៅក្នុងគ្រួសាររបស់ខ្ញុំ។

កៈ
រឿងសប្បាយចិត្តអ៊ុំដូចជារឿងដែលធ្វើអោយអ៊ុំបានសប្បាយចិត្តដូចថាពេលដែលអ៊ុំបាននឹកឃើញហើយនឹងធ្វើអោយអ៊ុំពេលខ្លះចឹងទៅបានអង្គុយសោចម្នាក់ឯងអីចឹងពេលខ្លះចឹងទៅណា។

ខៈ
អត់មានទេអត់មានរឿងដែលនឹងឃើញហើយនឹងអង្គុយសើចម្នាក់ឯនោះទេណានឹងគេហៅថាមនុស្សឆ្កួតហើយអានឹងនោះ។

ក៖ ហាហា

ខ៖ ហាហ

ក៖
ព្រោះអីដូចថាមានរឿងខ្លះចឹងទៅវាធ្វើអោយអ៊ុំរំភើបពេកដល់ចឹងទៅពេលនឹងវាបានធ្វើអោយអ៊ុំបានធ្លាប់ជួបមកនឹងចឹងថាចឹងពេលដែលអ៊ុំបាននឹងឃើញអំពីរឿងនឹងហើយនឹងធ្វើអោយអ៊ុំបានសប្បាយចិត្តនឹងរឿងនឹងចឹងណា។

ខ៖ ហឹស

ក៖ ដែលវាបានកើតឡើងនៅក្នុងជីវិតរបស់អ៊ុំណា។

ខ៖ វាមានហើយអារឿងសប្បាយនោះតែវាអត់មានដើរទៅសើចនោះទេហាហាហា

ក៖ ហាហា

ខ៖ ហាហ

ក៖ ចឹងអ៊ុំមានរឿងដែលធ្វើអោយអ៊ុំបានសប្បាយចិត្តដែលតើអ៊ុំ?

ខ៖ ខ្ញុំមានតើ

ក៖ ចឹងតើខ្ញុំនឹងអាចសួរអ៊ុំបានដែលឬទេថាតើរឿងទាំងអស់នឹងមានអ្វីគេខ្លះដែរទៅអ៊ុំ?

ខ៖
គឺថាយើងបានរាងធូអារម្មណ៏ពេលដែលកូនចៅយើងនឹងបានរាងមានហើយកូនចៅអីនឹងគេមានលុយសំរាប់ចាយអីនឹងចឹងទៅវាធ្វើអោយស្រួលទៅវាសប្បាយចិត្តហ៎វារាងស្រួលទៅចឹងនោះហើយបើថាកូនចៅនឹងវារាង
វាបានធ្វើអោយលំបាកព្រោះអីកូនចៅនឹងវាអត់មានលុយអីនឹងសំរាប់អោយចាយនឹងក៏វារាងពិបាកដែលហើយវាធ្វើអោយយើងនឹងពិបាកចិត្តទៅវាមានតែប៉ុណ្ណឹងទេ។

ក៖

ចាសអ៊ុំមានជាពាក្យពេជ្រអ្វីនឹងដើម្បីធ្វើការផ្ដាំផ្ញើរដល់កូនចៅក៏ដូចជាអ្នកដែលគេបានស្ដាប់សំលេងរបស់អ៊ុំ១នឹងណា។

ខ៖

ចាសអោយពរបងប្អូនដែលបានស្ដាប់សំលេងខ្ញុំដែលបានធ្វើការសំភាសន៏នេះអោយបានសុខចំរើនអោយបានទៅធ្វើការងារនៅកន្លែងណាអោយបានសមប្រកបបានដូចសេចក្ដីប្រាថ្នា។

ក៖ ចាសចឹងអ៊ុំមានពាក្យអ្វីដើម្បីនឹងបន្ថែមទៀតដែលឬទេអ៊ុំ?

ខ៖

អស់ហើយមិនដឹងថានឹងត្រូវមានពាក្យអីនឹងទៀតទេព្រោះអីខ្ញុំវាមិនសូវជានឹងចេះនិយាយអីនឹងផងងាហាហា។

ក៖

ចាសតែអ៊ុំខ្ញុំបានមើលឃើញថាអ៊ុំដូចជាមានការសប្បាយចិត្តច្រើនចឹងដូចជាអ៊ុំដែលមានទុក្ខនឹងច្រើនហើយព្រមទាំងគ្រួសារអីនឹងដែលត្រូវទេអ៊ុំនេស?

ខ៖

ឥឡូវនឹងអ៊ុំវាវាងថាចាស់ណាស់ទៅហើយចឹងហើយវាលែងបានសូវជាអារម្មណ៏អីចឹងទៅហើយ

ក៖ អូចឹង

ខ៖

វាលែងសូវបានកើតទុក្ខចឹងហើយបានជាវាធ្វើអោយយើងនឹងមានអាយុវាវាងបានវែងបន្តិចដែរ។

ក៖ ចាសអ៊ុំចឹងអ៊ុំមានបានចូលចិត្តស្ដាប់បទចម្រៀងដែលឬទេ?

ខ៖

ហឹកូននឹងវាចេះតែបើកទូរទស្សន៍អីចឹងទៅខ្ញុំនឹងវាចេះតែបានមើលចឹងទៅតែខ្ញុំនឹងវាមិនបាននឹងមើលនឹងគេនឹងបានយូរនោះទេព្រោះអីវាចេះតែចុកភ្នែកវាចេះតែចុក។

ក៖

ចាសហើយចុះកាលនៅក្នុងកាលនៅសម័យកាលពីដើមនឹងឡើយនឹងអ៊ុំធ្លាប់បានស្តាប់បទចម្រៀងដែរទេ?

ខ៖ ហឹសកាលនៅកាលពីដើមឡើយនឹងខ្ញុំវាសូវទេ
ហើយកាលនៅពីក្មេងនឹងវាដើរមិនសូវបានដូចជាបានធុំខ្លិនទឹកអប់អីនឹងវាអត់បានទេវាចេះតែក្អួតតែម្តងហើយចឹងទៅបើថាអោយទៅមើលល្បែងល្បាំងអីនឹង
ម្តាយរបស់ខ្ញុំនឹងគាត់មិនសូវជាអោយយើងនឹងទៅនោះទេកាលនឹងព្រោះអីពេលដែលបានធុំខ្លិននឹងទៅវាចេះតែក្អួតអីចឹងខ្លាចវាទន់ខ្លួនចឹងខ្លាចវាក្អួតហើយទន់ខ្លួនចឹងវាពិបាកគេនឹងយកមកផ្ទះគ្មានតើអ្នកណាគេបានយកយើងមកផ្ទះ។
ចឹងហើយកាលនឹងអ៊ុំមិនសូវបានដើរទេកាលនៅពីក្មេងឡើងមក។

ក៖

ចាសហើយចុះកាលនឹងចំពោះល្បែងៗកាលពីនៅតូចៗនឹងតើអ៊ុំធ្លាប់បាននឹងលេងដែលឬទេ?

ខ៖ អត់ទេកាលនឹងមានលេងតែបាយឡុកបាយឡអីនឹងកាលនឹង។

ក៖ អូចឹងកាលនឹងមានលេងនឹងដូចជាមានបាយឡុកបាយឡអីនឹងកាលនឹង។

ខ៖

នឹងហើយកាលនឹងមានតែចឹងហើយថាបើរាំអីនឹងវាមិនចេះទៅរាំអីនឹងគេនោះទេកាលនឹងនោះ។

ក៖

ហើយចុះអ៊ុំចំណែកឯមិត្តភក្តិរបស់អ៊ុំវិញកាលនឹងតើអ៊ុំមានបាននៅតែរាប់អានគ្នាហើយអ៊ុំពីមុនមកដល់ឥឡូវនឹងមានបាននៅតែនឹងឃើញគ្នាហើយអ៊ុំមានបាននៅចាំឈ្មោះរបស់ពួកគាត់ដែលឬទេ?

ខ៖
អត់បានបែកគ្នាអស់ហើយគេបានបែកគ្នាហើយគេបានទៅនៅឯស្រុកណានែអស់ចឹងហើយនឹងយើងនឹងក៏បានបែកមកការនៅស្រុកផ្សេងចឹងអស់ហើយនឹងចឹង
ចឹងហើយបានបែកគ្នាអស់ហើយ។

ក៖ ចាស ចុះចឹងឥឡូវនឹងតែ១នាក់នឹងក៏អ៊ុំអត់មានដែលចឹង?

ខ៖ អត់

ក៖ ចឹងមានតែអ្នកនៅជិតៗខាងចឹងអ៊ុំណ៎?

ខ៖ ចាសមានតែអ្នកដែលនៅជិតៗខាងនឹង។

ក៖
អូចាសចឹងថ្ងៃនេះសូមអរគុណអ៊ុំច្រើនដែលអ៊ុំបានធ្វើការចំណាយពេលដើម្បីនឹងអោយខ្ញុំធ្វើការសំលេងហើយនឹងបានដាក់សំលេងរបស់អ៊ុំចុលទៅក្នុងវេបសាយរបស់ខាងសាលារបស់សាលាBYU Hawiaនៅខាងសហរដ្ឋអាមេរិកណាអ៊ុំ។

ខ៖ ចាស

ក៖
ចាសចឹងខ្ញុំសូមការអនុញ្ញាតពីអ៊ុំស្រីផ្ទាល់ដើម្បីនឹងធ្វើការអនុញ្ញាតពីអ៊ុំស្រីផ្ទាល់យកទៅដាក់នៅក្នុងវេបសាយរបស់ខាងសាលាដើម្បីយកទៅសាលាគេបានធ្វើការដូចជាបកប្រែនឹងធ្វើការត្រួតពិនិត្យមើលឡើងវិញម្តងទៀងហើយនឹងធ្វើការអើ
ធ្វើការសំរបសំរួលនៅក្នុងសំលេង១នេះដូចជាមានការបកប្រែជាភាសាអង់គ្លេសនឹងធ្វើការដាក់នៅក្នុងវេបសាយរបស់ខាងសាលាផ្ទាល់តែម្តង
ចាសចឹងខ្ញុំសូមសួរអ៊ុំម្តងទៀតជាចុងក្រោយចឹងតើខ្ញុំអាចសុំសំលេងរបស់អ៊ុំដែលបានធ្វើការrecordដើម្បីនឹងដាក់សំលេងរបស់អ៊ុំនៅក្នុងវេបសាយនឹងដែលឬទេអ៊ុំ?

ខ៖ ហាស?

ក៖ ដើម្បីនឹងធ្វើការដាក់សំលេងរបស់អ៊ុំនៅក្នុងវេបសាយនឹងដែលឬទេអ៊ុំ?

ខ៖ ហាសសំលេងនឹងដែលបានសំភាសន៍នឹងហើយនឹងទៅហើយនឹង។

ក៖
ចាសការសំភាសន៍ហើយអស់ហើយខ្ញុំក៏បានសួរអ៊ុំកាលពីមុនសំភាសន៍នឹងដែលអ៊ុំប៉ុន្តែខ្ញុំសូមធ្វើការបញ្ជាក់ជាមួយនឹងអ៊ុំជាចុងក្រោយណាអ៊ុំតើអ៊ុំបានអនុញ្ញាតដើម្បីនឹងអោយខ្ញុំបានដាក់សំលេងរបស់អ៊ុំស្រីនៅក្នុងនឹងដែលឬទេអំពីជីវៈប្រវត្តិរបស់អ៊ុំអីនឹងដើម្បីនឹងអោយកូនចៅជំនាន់ក្រោយទៀតនឹងគេបានស្ដាប់?

ខ៖
អានឹងវាស្រាចតែអ្នកគ្រូនឹងដែលទេបើថាអាចដាក់បានទៅជឿនលឿនទេក៏ដាក់ទៅហើយបើថាវាមិនជាជឿនលឿននោះទេអត់បានប្រយោជន៍អីនោះទេក៏ចោលទៅ។

ក៖
ចាសនឹងហើយអ៊ុំចាសអរគុណអ៊ុំដូចថាអ៊ុំមានជីវៈប្រវត្តិមួយដល់អស្ចារ្យដែលក្មេងជំនាន់ក្រោយទៀតនឹងគេមិនបានដឹងចឹងណាអ៊ុំចឹងហើយបានជាគោលបំណងនៃការសំភាសន៍មួយនឹងគេចង់ទុកអោយកូនចៅជំនាន់ក្រោយមកទៀតនឹងគេបានដឹងដែលជាពិសេសកូនចៅរបស់អ៊ុំទេចាស។ ចាសអ៊ុំសូមអរគុណអ៊ុំស្រីច្រើនសំរាប់ថ្ងៃនេះ។

ខ៖ ចាសៗអរគុណច្រើនសូមអោយសុខសប្បាយ។